ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

តុលាការរដ្ឋប្បវេណី

- សាលក្រមលេខៈ ៨៨ "ម"
ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣។
- សំណុំរឿងរដ្ឋប្បវេណីលេខ ១៨២៧
ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២២។

## សាលក្រម

### ក្នុងនាមប្រជារាស្ត្រខ្មែរ

### សាលាដំបូងរាជធានីភ្នំពេញ

បញ្ចប់ការទាញហេតុដោយផ្ទាល់មាត់ នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣។

**ចៅក្រមជំនុំជម្រះ**

លោក [redacted] អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ។

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជី សាលាដំបូងរាជធានីភ្នំពេញ។

**ដើមចោទៈ** ឈ្មោះ [redacted] លីចិន ភេទស្រី អាយុ ៤៤ឆ្នាំ សញ្ជាតិខ្មែរ អាសយដ្ឋាន [redacted]។ ទូរស័ព្ទ 017 89 87 27

**អ្នកតំណាងដោយអាណត្តិ**

មេធាវី [redacted] និងមេធាវី [redacted] មានក្រុមហ៊ុនមេធាវី [redacted]។

**ចុងចម្លើយៈ** ឈ្មោះ [redacted] សុភា ភេទស្រី អាយុ ៣៤ឆ្នាំ សញ្ជាតិខ្មែរ [redacted]

## អង្គហេតុ និងចំណុចវិវាទ

**ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ**

១. បង្គាប់ឱ្យចុងចម្លើយសងប្រាក់ដើមចំនួន ១៥០.០០០ (ដប់ប្រាំម៉ឺន) ដុល្លារអាមេរិក ឱ្យទៅដើមចោទ។

២. បង្គាប់ឱ្យចុងចម្លើយបង់ការប្រាក់ ក្នុងរយៈពេល ១១ខែ ស្មើនឹងទឹកប្រាក់ចំនួន ២៤.៧៥០ (ពីរម៉ឺនបួនពាន់ប្រាំពីររយហាសិប) ដុល្លារអាមេរិក និងការប្រាក់បន្ថែម រហូតដល់ថ្ងៃសងប្រាក់ដើមរួច។

៣. បង្គាប់ឱ្យចុងចម្លើយសងសំណងការខូចខាតចំនួន ៨២.០០០.០០០ (ប៉ែតសិបពីរលាន) រៀល ឱ្យទៅដើមចោទ។

៤. ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

៥. សុំឱ្យប្រកាសសាលក្រមនេះអាចអនុវត្តជាបណ្ដោះអាសន្នបាន ត្រង់ចំណុចទី១ នៃការទាមទារនេះ ស្របតាមបញ្ញត្តិមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។



អាសយដ្ឋានៈ អាគារលេខ ២៥ ផ្លូវលេខ ២១៧ សង្កាត់វាលវង់ ខណ្ឌ ៧ មករា, ភ្នំពេញ
Adress: #25, Street 217, Sangkat Vealvong, Khan 7makara, Phnom Penh, Cambodia.
ទូរសារ-ទូរស័ព្ទៈ (៨៥៥)-២៣ ៨៨ ២០ ៥៩
Fax-Phone : (855) - 23 88 20 59

Scanned with CamScanner

## ខ. ដំណើររឿងក្តី និងអង្គហេតុដែលគ្មានវិវាទ

### ខ.១ ការសង្ខេបរឿងក្តី

ក្នុងរឿងក្តីនេះ កាលពីថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២១ ដើមចោទ បានចុះកិច្ចសន្យាខ្ចីបរិភោគ ដោយមានការប្រាក់ចំនួន ១,៥% (មួយក្បៀសប្រាំភាគរយ) ក្នុង ១ខែ នៃប្រាក់ដើមចំនួន ១៥០.០០០ (ដប់ប្រាំម៉ឺន) ដុល្លារអាមេរិក និងផុតកំណត់នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២២ ត្រូវត្រឡប់មកវិញទាំងប្រាក់ដើម និងការប្រាក់។ ប៉ុន្តែ ក្រោយការអនុវត្តកាតព្វកិច្ចរបស់ដើមចោទរួចមក ចុងចម្លើយបានបង់ការប្រាក់ចំនួន៣ដងតែប៉ុណ្ណោះ ហើយក៏ឈប់បង់ការប្រាក់តែម្តង។ ដូច្នេះ ដើមចោទទាមទារសុំឱ្យតុលាការចេញសាលក្រមបង្គាប់ឱ្យចុងចម្លើយសងប្រាក់ដើម និងការប្រាក់ ឱ្យទៅដើមចោទ ព្រមទាំងសំណងការខូចខាតផ្សេងទៀត។

### ខ.២ អង្គហេតុដែលគ្មានវិវាទ

ខ.២.១ ចុងចម្លើយទទួលស្គាល់ថា បានបង្កើតកិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ តាមរយៈកិច្ចព្រមព្រៀងខ្ចីប្រាក់ ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២១ ជាមួយនឹងដើមចោទ ដែលមានប្រាក់ដើមចំនួន ១៥០.០០០ (ដប់ប្រាំម៉ឺន) ដុល្លារអាមេរិក។

ខ.២.២ ចុងចម្លើយទទួលស្គាល់ចំពោះការទាមទារការប្រាក់ចំនួន ១,៥% (មួយក្បៀសប្រាំភាគរយ) ក្នុង ១ខែ នៃប្រាក់ដើមចំនួន ១៥០.០០០ (ដប់ប្រាំម៉ឺន) ដុល្លារអាមេរិក។

ខ.២.៣ ចុងចម្លើយទទួលស្គាល់ថា ក្រោយពេលចុះកិច្ចព្រមព្រៀងខ្ចីប្រាក់រួចមក ចុងចម្លើយបង់ការប្រាក់ជូនដើមចោទត្រឹមចំនួន ៣ដងដំបូង ហើយក៏ឈប់បានបង់ការប្រាក់ចាប់តាំងពីពេលនោះមក ព្រោះថាចុងចម្លើយអលទ្ធភាព។

## គ. សេចក្តីថ្លែងការណ៍របស់ដើមចោទ

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក៏ដូចជានីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ អ្នកតំណាងដោយអាណត្តិរបស់ដើមចោទ មេធាវី [redacted]និងមេធាវី [redacted]បានធ្វើសេចក្តីថ្លែងការណ៍អំពីអង្គហេតុនៃការទាមទារ ដូចខាងក្រោមថា៖

> *...I.អំពីអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ*
>
> *(១)-កាលពីថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២១ ចុងចម្លើយឈ្មោះ ចាន់ សុភា បានចុះកិច្ចព្រមព្រៀង ខ្ចីប្រាក់ជាមួយចុងចម្លើយឈ្មោះ [redacted]លីចិន ក្នុងទឹកប្រាក់ចំនួន ១៥០.០០០ (ដប់ប្រាំម៉ឺន) ដុល្លារអាមេរិក ដោយបង់ការប្រាក់ប្រចាំខែ ១.៥% នៃប្រាក់ដើម ស្មើនឹងចំនួន ២.២៥០ (ពីរពាន់ពីររយហាសិប) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២១។*
>
> *(២)-ក្រោយពីបានចុះកិច្ចព្រមព្រៀងនេះ និងបានប្រគល់ប្រាក់កម្ចីរួចមក ចុងចម្លើយបង់ការប្រាក់ជូនដើមចោទ ចំនួន៣ខែ គិតចាប់ពីខែសីហា ឆ្នាំ២០២១ ដល់ខែតុលា ឆ្នាំ២០២១។ ក្រោយមក ចុងចម្លើយក៏ខកខានបង់ការប្រាក់ឱ្យឱ្យដើមចោទ ទោះបីជាដើមចោទបានដាស់តឿនឱ្យសងប្រាក់យ៉ាងណាក៏ដោយ។ ការប្រាក់សរុបដែលអាក់ខានបង់នោះ មានចំនួន១១ខែ គិតត្រឹម*

ខែតុលា ឆ្នាំ២០២២ ស្មើនឹងទឹកប្រាក់ចំនួន ២៤.៧៥០ (ម្ភៃបួនពាន់ ប្រាំពីររយហាសិប) ដុល្លារអាមេរិក។

(៤)-ដោយហេតុថា ចុងចម្លើយបានបំពានកាតព្វកិច្ចបង់ការប្រាក់តាមកិច្ចព្រមព្រៀងជាច្រើនខែ និងបានធ្វើការដាស់តឿនជាច្រើនលើកច្រើនសារ ឱ្យចុងចម្លើយសងប្រាក់ដើម និងការប្រាក់ តែចុងចម្លើយនៅតែមិនអនុវត្តកាតព្វកិច្ចតាមកិច្ចព្រមព្រៀងនោះឡើយ ដែលធ្វើឱ្យដើមចោទខាតបង់ផលប្រយោជន៍យ៉ាងធ្ងន់ធ្ងរ។ ដើមចោទ បានទាមទារឱ្យចុងចម្លើយប្រមូលប្រាក់ ដើម្បីសងទាំងប្រាក់ដើម និងការប្រាក់ដែលជំពាក់ ដែលមានទឹកប្រាក់សរុបចំនួន ១៧៤.៧៥០ (ដប់ប្រាំពីរម៉ឺនបួនពាន់ប្រាំពីររយហាសិប) ដុល្លារអាមេរិក ប៉ុន្តែចុងចម្លើយនៅតែមិនព្រមសងប្រាក់ និងមិនទទួលខុសត្រូវចំពោះកាតព្វកិច្ចរបស់ខ្លួនឡើយ។

II.អំពីអង្គច្បាប់

(១)-យោងតាមមាត្រា ៥៧៨ នៃក្រមរដ្ឋប្បវេណី "ការខ្ចីបរិភោគ សំដៅទៅលើកិច្ចសន្យាមួយដែលភាគីម្ខាង ហៅថាអ្នកឱ្យខ្ចី មានករណីយកិច្ចប្រគល់ការប្រើប្រាស់ដោយសេរី នូវប្រាក់ស្បៀង អាហារ ឬវត្ថុជំនួសផ្សេងទៀត ក្នុងអំឡុងពេលដែលមានកំណត់ឱ្យទៅភាគីម្ខាងទៀត ហៅថាអ្នកខ្ចី ហើយនៅក្រោយពេលដែលអំឡុងពេលនោះបានកន្លងផុត អ្នកខ្ចីមានករណីយកិច្ចសងទៅឱ្យអ្នកឱ្យខ្ចីវិញនូវវត្ថុដែលមានប្រភេទ គុណភាព និងចំនួនស្មើគ្នានឹងវត្ថុដែលបានទទួលពីអ្នកឱ្យខ្ចីនោះ"។ យោងតាមកិច្ចព្រមព្រៀងខ្ចីប្រាក់ ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២១ បានបញ្ជាក់ថាដើមចោទ និងចុងចម្លើយបានព្រមព្រៀងគ្នាបង្កើតកិច្ចសន្យាខ្ចីប្រាក់ចំនួន១៥០.០០០ (ដប់ប្រាំម៉ឺន) ដុល្លារអាមេរិក ចំណុចនេះបញ្ជាក់ឱ្យឃើញថា ចុងចម្លើយឈ្មោះ [redacted] សុភា ពិតជាបានខ្ចីប្រាក់ចំនួន១៥០.០០០ (ដប់ប្រាំម៉ឺន) ដុល្លារអាមេរិក ប្រាកដមែន។ យោងមាត្រា ៥៧៩ "កិច្ចសន្យាខ្ចីបរិភោគត្រូវបានបង្កើតឡើង ដោយការព្រមព្រៀងរវាងអ្នកឱ្យខ្ចី និងអ្នកខ្ចីតែប៉ុណ្ណោះ"។

(២)-តាមអង្គហេតុខាងលើ ចុងចម្លើយបានខ្ចីប្រាក់ ១៥០.០០០ (ដប់ប្រាំម៉ឺន) ដុល្លារអាមេរិក ហើយត្រូវមានកាតព្វកិច្ចសងនូវប្រាក់ទាំងនោះ រួមទាំងការប្រាក់ ឱ្យទៅដើមចោទវិញ មិនដូច្នេះដើមចោទមានសិទ្ធិទាមទារឱ្យតុលាការបង្គាប់ឱ្យចុងចម្លើយសងទៅដើមចោទ។ យោងតាមមាត្រា ៣៨៤ កថាខណ្ឌ ១ នៃក្រមរដ្ឋប្បវេណី "កូនបំណុលត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួន ឱ្យស្របទៅតាមខ្លឹមសារនៃកិច្ចសន្យា និងគោលការណ៍នៃភាពសុចរិត និងភាពស្មោះត្រង់" និងមាត្រា ៣៨៥ កថាខណ្ឌ ១ នៃក្រមរដ្ឋប្បវេណី "ម្ចាស់បំណុលអាចទាមទារឱ្យកូនបំណុលអនុវត្តកាតព្វកិច្ចតាមផ្លូវតុលាការ"។

(៣)-ដូចមានបញ្ជាក់ជូនខាងលើ នៅក្នុងកិច្ចព្រមព្រៀងខ្ចីប្រាក់ គូភាគីបានឯកភាពគ្នាលើ ចំនួនអត្រាការប្រាក់ចំនួន ១៨%ក្នុងមួយឆ្នាំដែរ។ ចំណុចនេះ បើយោងតាមមាត្រា ៥៨៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី "អត្រាការប្រាក់ អាចកំណត់បានតាមបញ្ញត្តិច្បាប់ ឬ ដោយការព្រមព្រៀងរបស់ភាគី"។ យើងខ្ញុំសុំកែតម្រូវចំណុចទាមទារឱ្យសងការប្រាក់ សុំឱ្យចុងចម្លើយសងការប្រាក់



Scanned with CamScanner

រហូតដល់ថ្ងៃសងប្រាក់ដើមគ្រប់ចំនួន ព្រោះដោយហេតុថា កូនក្តីរបស់យើងខ្ញុំខកខានទទួលការប្រាក់ អស់រយៈពេល១៣ខែហើយ រហូតមកដល់ពេលនេះ។

(៤)-ដោយហេតុថា ដើមចោទ ក៏បានដាស់តឿនចុងចម្លើយអំពីការខកខានបង់ការប្រាក់ប្រចាំខែឱ្យទៅដើមចោទចាប់ពីខែវិច្ឆិកា ឆ្នាំ២០២១ រហូតមកដល់ខែតុលា ឆ្នាំ២០២២ សរុបចំនួន១១ខែ ស្មើនឹងទឹកប្រាក់ចំនួន ២៤,៧៥០ (ពីរម៉ឺនបួនពាន់ប្រាំពីររយហាសិប) ដុល្លារអាមេរិក។ ការខកខានបង់ការប្រាក់ប្រចាំខែបែបនេះ គឺធ្វើឱ្យខាតបង់ផលប្រយោជន៍ កូនក្តីយើងខ្ញុំយ៉ាងធ្ងន់ធ្ងរ ដូចនេះ កូនក្តីយើងខ្ញុំមានសិទ្ធិទាមទារសំណងជម្ងឺចិត្ត ការខូចខាត និងការចំណាយផ្សេងៗ ដូចដែលបានបញ្ជាក់ជូនខាងលើ។ យោងតាមមាត្រា ៤០៨ កថាខណ្ឌ ១ ចំណុច ក នៃក្រមរដ្ឋប្បវេណី។

(៥)-រឿងក្តីនេះ គឺជារឿងក្តីដែលទាមទារសិទ្ធិលើទ្រព្យសម្បត្តិឱ្យសងប្រាក់កម្ចី ហើយមានភស្តុតាងគ្រប់គ្រាន់ ក្នុងការទទួលស្គាល់នូវការអះអាងរបស់ភាគីដើមចោទ។ ដូចនេះ ដើមចោទស្នើសុំនូវការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ដោយយោងតាមមាត្រា ១៩៦ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

(៦)-យោងតាមកំណត់ហេតុស្តីពី នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០២៣ ចុងចម្លើយបានទទួលស្គាល់ថា ពិតជាបានខ្ចីប្រាក់ចំនួន ១៥០.០០០ (ដប់ប្រាំម៉ឺន) ដុល្លារអាមេរិក ពីដើមចោទប្រាកដមែន ដោយបានផ្តិតម្រាមដៃលើកិច្ចព្រមព្រៀងខ្ចីប្រាក់ ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២១ ។

III.សេចក្តីសន្និដ្ឋាន និង សំណូមពរ

យោងតាមអង្គហេតុ អង្គច្បាប់ខាងលើ និងយោងតាមកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០២៣ បញ្ជាក់ថា ចុងចម្លើយបានទទួលស្គាល់ថា ពិតជាបានខ្ចីប្រាក់ចំនួន ១៥០.០០០ (ដប់ប្រាំម៉ឺន) ដុល្លារអាមេរិក ពីដើមចោទប្រាកដមែន និងដោយបានឯកភាពគ្នាលើ ចំនួនអត្រាការប្រាក់ចំនួន ១៨% ក្នុង១ឆ្នាំ។ ចំណុចនេះបើយោងតាមមាត្រា ៥៨៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី “អត្រាការប្រាក់ អាចកំណត់បានតាមបញ្ញត្តិច្បាប់ ឬដោយការព្រមព្រៀងរបស់ភាគី”។ ការខកខានបង់ការប្រាក់ជាច្រើនខែបែបនេះ គឺធ្វើឱ្យខាតបង់ផលប្រយោជន៍ កូនក្តីយើងខ្ញុំយ៉ាងធ្ងន់ធ្ងរ។ ហេតុដូច្នេះ ក្នុងនាមជាអ្នកតំណាងដោយអាណត្តិរបស់ដើមចោទ ស្នើសុំឱ្យតុលាការចេញសាលក្រមសម្រេចសេចក្តីដូចខាងក្រោម៖

១-បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] សុភា សងប្រាក់ដើមចំនួន ១៥០.០០០ (ដប់ប្រាំម៉ឺន) ដុល្លារអាមេរិក មកឱ្យដើមចោទឈ្មោះ [redacted] លីចិន។ ២-បង្គាប់ឱ្យចុងចម្លើយសងការប្រាក់ដែលជំពាក់សរុបចំនួន១១ខែ ស្មើនឹង ២៤.៧៥០ (ម្ភៃបួនពាន់ប្រាំពីរហាសិប) ដុល្លារអាមេរិក ក្នុងអត្រាការប្រាក់ ១៨% (ដប់ប្រាំបី ភាគរយ) ក្នុង ១ឆ្នាំ គិតត្រឹមខែតុលា ឆ្នាំ២០២២ និងការប្រាក់បូកបន្ថែម រហូតដល់ថ្ងៃសងប្រាក់ដើមគ្រប់ចំនួន មកឱ្យដើមចោទឈ្មោះ [redacted] លីចិន។ ៣-បង្គាប់ឱ្យចុងចម្លើយសងសំណងជម្ងឺចិត្ត និងសំណងការខូចខាតចំនួន ៨២.០០០.០០០ (ប៉ែតសិបពីរ) លានរៀល។ ៤-សុំឱ្យតុលាការប្រកាសសាលក្រមអាចអនុវត្តជាបណ្តោះអាសន្នបាន



Scanned with CamScanner

*ត្រង់ចំណុចទី ១ នៃការទាមទារខាងលើនេះ ស្របតាមបញ្ញត្តិមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ៥-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។*

**ឃ. សេចក្ដីថ្លែងការណ៍តបរបស់ចុងចម្លើយ**

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក៏ដូចជានីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ចុងចម្លើយ ឈ្មោះ [redacted]សុភា បានធ្វើសេចក្ដីថ្លែងការណ៍តប ដូចខាងក្រោមថា ៖

*នាងខ្ញុំទទួលស្គាល់នូវការទាមទាររបស់ដើមចោទ ត្រង់ចំណុចទី១ ដែលទាមទារឱ្យសងប្រាក់ដើមចំនួន ១៥០.០០០ (ដប់ប្រាំម៉ឺន) ដុល្លារអាមេរិក។ ចំពោះការប្រាក់ និងសំណងនៃការខូចខាតដូចការទាមទារនោះ នាងខ្ញុំសូមបដិសេធ ព្រោះថានាងខ្ញុំពុំមានលទ្ធភាពសងទេ។ នាងខ្ញុំទទួលស្គាល់ថាពិតជាបានខ្ចីប្រាក់ និងយល់ព្រមបង់ការប្រាក់ដូចការអះអាងរបស់ដើមចោទ ហើយម្យ៉ាងទៀត នាងខ្ញុំពិតជាពុំបានបង់ការប្រាក់ជូនដើមចោទ ប្រាកដមែន។ នាងខ្ញុំបានបង់ការប្រាក់ជូនដើមចោទបានចំនួន ៣ដងដែរ ហើយក្រោយមក ដោយសារបញ្ហាកូវីដផង ហើយស្វាមីទទួលមរណភាពទៀត ទើបពុំមានលទ្ធភាពរកប្រាក់សងដើមចោទបាននោះឡើយ។*

*នាងខ្ញុំបដិសេធចំពោះការទាមទារឱ្យសងការខូចខាត ព្រោះថា សូម្បីតែការប្រាក់ និងប្រាក់ដើមនាងខ្ញុំពុំមានលទ្ធភាពសងផង តើនាងខ្ញុំមានអ្វីដើម្បីសងការខូចខាតរហូតដល់ ៨២.០០០.០០០ (ប៉ែតសិបពីរលាន) រៀល ជូនដើមចោទបានយ៉ាងដូចម្ដេច។ បច្ចុប្បន្ននេះ នាងខ្ញុំពុំមានមុខរបរទេ ហើយទំនេរនៅផ្ទះ។ ដូច្នេះ នាងខ្ញុំពុំដឹងថា ពេលណាទេ ទើបមានលទ្ធភាពសងប្រាក់ដើមចោទនោះឡើយ។*

## សំអាងហេតុ

**I. ការវិនិច្ឆ័យចំពោះការទាមទារ**

១. តាមអង្គហេតុគ្មានវិវាទរបស់គូភាគី ដែលជាកិច្ចសន្យាខ្ចីបរិភោគដោយមានការប្រាក់ តាមរយៈកិច្ចព្រមព្រៀងខ្ចីប្រាក់ ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២១ ដោយក្នុងនោះ ប្រាក់ដើមមានចំនួន ១៥០.០០០ (ដប់ប្រាំម៉ឺន) ដុល្លារអាមេរិក និងការប្រាក់ ១៨% (ដប់ប្រាំបីភាគរយ) ក្នុង ១ឆ្នាំ ឬ ១,៥% (មួយក្បៀសប្រាំភាគរយ) ក្នុង ១ខែ។ ដូច្នេះ តុលាការទទួលស្គាល់ថា កិច្ចសន្យាខ្ចីបរិភោគដោយមានការប្រាក់នេះ ត្រូវបានបង្កើត និងមានអនុភាពស្របតាមបញ្ញត្តិមាត្រា ៥៧៩ មាត្រា ៥៨៣ និងមាត្រា ៥៨៤ នៃក្រមរដ្ឋប្បវេណី និងស្របតាមប្រការ ១ នៃប្រកាសរបស់ក្រសួងយុត្តិធម៌លេខ ១២៨ កយ.ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ស្ដីពីអត្រាការប្រាក់ដែលត្រូវបានកម្រិត។

២. ជាងនេះទៅទៀត ចុងចម្លើយបានទទួលស្គាល់ថា ខ្លួនពិតជាបានខ្ចីប្រាក់ចំនួន ១៥០.០០០ (ដប់ប្រាំម៉ឺន) ដុល្លារអាមេរិក និងខានបង់ការប្រាក់ដូចការអះអាងរបស់ដើមចោទ ប្រាកដមែន។ ដូច្នេះ គប្បីតុលាការសម្រេចទទួលស្គាល់នូវការទាមទាររបស់ដើមចោទ ត្រង់ចំណុចប្រាក់ដើមចំនួន ១៥០.០០០ (ដប់ប្រាំម៉ឺន) ដុល្លារអាមេរិក ស្របតាមបញ្ញត្តិមាត្រា ៥៧៨ នៃក្រមរដ្ឋប្បវេណី។



Scanned with CamScanner

៣. ចំពោះការទាមទាររបស់ដើមចោទ ដែលសុំឱ្យតុលាការសម្រេចអត្រាការប្រាក់រហូតដល់ថ្ងៃសងប្រាក់ដើមរួចនោះ តុលាការគប្បីមិនពិចារណា នឹងសម្រេចទេ។ ទោះជាយ៉ាងណា តុលាការទទួលស្គាល់ត្រឹមអត្រាការប្រាក់ ១,៥% (មួយក្បៀសប្រាំភាគរយ) ក្នុង ១ខែនេះ ដោយគិតចាប់ពីថ្ងៃខកខានបង់ការប្រាក់ ថ្ងៃទី៧ ខែតុលា ឆ្នាំ២០២១ រហូតដល់ថ្ងៃដាក់ពាក្យបណ្តឹងរបស់ដើមចោទ នៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២២ តែប៉ុណ្ណោះ ស្របតាមស្មារតីនៃក្រមរដ្ឋប្បវេណី។

៤. ចំពោះការទាមទាររបស់ដើមចោទ ដែលសុំឱ្យតុលាការបង្គាប់ឱ្យចុងចម្លើយសងការខូចខាតចំនួន ៨២.០០០.០០០ (ប៉ែតសិបពីរលាន) នោះ តុលាការពិនិត្យឃើញថា ពុំមានភស្តុតាងបញ្ជាក់ច្បាស់លាស់អំពីការខូចខាតដល់កម្រិតនេះនោះឡើយ។ ប៉ុន្តែ ដោយពិចារណាលើការចូលរួមក្នុងដំណើរការនីតិវិធីជាក់ស្តែង តុលាការទទួលស្គាល់ការទាមទារនេះ ត្រឹមមួយផ្នែក គឺ ចំនួន ១៦.០០០.០០០ (ដប់ប្រាំមួយលាន) រៀល។

## II. បន្ទុកនៃប្រាក់ប្រដាប់ក្តី

ដោយតុលាការទទួលស្គាល់ការទាមទាររបស់ដើមចោទ ដូច្នេះ គប្បីចុងចម្លើយត្រូវទទួលបន្ទុកប្រាក់ប្រដាប់ក្តី ស្របតាមបញ្ញត្តិមាត្រា ៦៤ កថាខណ្ឌ ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## III. ការអនុវត្តជាបណ្តោះអាសន្ន

ដោយហេតុថា តុលាការទទួលស្គាល់នូវការទាមទាររបស់ដើមចោទដែលជាសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ហើយតុលាការយល់ឃើញថា មានភាពចាំបាច់ក្នុងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ននោះ តុលាការគប្បីប្រកាសថា សាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នបាន គ្រប់ចំណុចស្តីពីសិទ្ធិលើបំណុលរបស់ដើមចោទចំពោះចុងចម្លើយជាប្រាក់ចំនួន ១៥០.០០០ (ដប់ប្រាំម៉ឺន) ដុល្លារអាមេរិក ស្របតាមបញ្ញត្តិមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

# សេចក្តីសម្រេចបញ្ចប់

១. បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] សុភា សងប្រាក់ដើមចំនួន ១៥០.០០០ (ដប់ប្រាំម៉ឺន) ដុល្លារអាមេរិក ទៅឱ្យដើមចោទឈ្មោះ [redacted] លីចិន។

២. បង្គាប់ឱ្យចុងចម្លើយបង់ការប្រាក់ចំនួន ១,៥% (មួយក្បៀសប្រាំភាគរយ) ក្នុង ១ខែ នៃប្រាក់ដើមចំនួន ១៥០.០០០ (ដប់ប្រាំម៉ឺន) ដុល្លារអាមេរិក ឱ្យទៅដើមចោទ គិតចាប់ពីថ្ងៃខកខានការប្រាក់ ថ្ងៃទី៧ ខែតុលា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២២។ ការទាមទារលើសពីនេះ ច្រានចោល។

៣. បង្គាប់ឱ្យចុងចម្លើយសងសំណងការខូចខាតចំនួន ១៦.០០០.០០០ (ដប់ប្រាំមួយលាន) រៀល។ ការទាមទារលើសពីនេះ ច្រានចោល។

៤. ឱ្យចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្តី។



Scanned with CamScanner

៥. សាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នបាន ត្រង់ចំណុចទី១ នៃសេចក្តីសម្រេចបញ្ចប់នេះ ស្របតាមបញ្ញត្តិមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

សាលក្រមនេះ ត្រូវបានប្រកាសជាសាធារណៈ នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣។ ក្នុងករណីដែលត្រូវប្តឹងឧទ្ធរណ៍ ត្រូវធ្វើឡើងក្នុងរយៈពេល១ (មួយ) ខែ ចាប់ពីថ្ងៃទទួលបានការបញ្ជូនលិខិតសាលក្រមនេះ។

ថ្ងៃអង្គារ ១០ កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣

ហត្ថលេខា និងត្រា៖ [redacted]

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ១០ កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣

**ចៅក្រម**

[redacted]



Scanned with CamScanner